ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៦.......សហវ.[illegible]

# សេចក្តីណែនាំ

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់មុខងាររៀបចំផែនការថវិកា តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់ក្រសួង-ស្ថាប័នចំនួន ១៤ រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ៩

មុខងាររៀបចំផែនការថវិកា នៃ FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងនៅជំហានដំបូង ក្នុងក្របខ័ណ្ឌថវិកាថ្នាក់ជាតិកាលពីខែ កក្កដា ឆ្នាំ ២០២១ នៅក្រសួងចំនួន២គឺ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងកិច្ចការនារី រួមជាមួយនឹងនាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើ **អនុមុខងាររៀបចំចំណាយថវិកា** ។ មុខងាររៀបចំផែនការថវិកា មានអនុមុខងារចំនួន ៩ គឺ ១-អនុមុខងាររៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, ២-អនុមុខងាររៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យម, ៣-អនុមុខងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា, ៤-អនុមុខងាររៀបចំចំណូលថវិកា, ៥-អនុមុខងាររៀបចំចំណាយថវិកា, ៦-អនុមុខងាររៀបចំប្រាក់បៀវត្សមន្ត្រីរាជការ, ៧-អនុមុខងាររៀបចំសូចនាករសមិទ្ធកម្ម, ៨-អនុមុខងាររៀបចំចំណាយថវិកាមូលធន និង ៩-អនុមុខងាររៀបចំចំណាយថវិកាការទូទាត់ការខ្ចី ។

ចាប់ពីឆ្នាំ ២០២១ មកដល់ ឆ្នាំ ២០២៤ មុខងាររៀបចំផែនការថវិកា ត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្រសួង-ស្ថាប័នសរុបចំនួន ២៣ (រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ) និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ទាំង២៥ លើអនុមុខងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា, អនុមុខងាររៀបចំចំណូលថវិកា, អនុមុខងាររៀបចំចំណាយថវិកា, អនុមុខងាររៀបចំប្រាក់បៀវត្សមន្ត្រីរាជការ និង អនុមុខងាររៀបចំសូចនាករសមិទ្ធកម្ម ។ ទន្ទឹមគ្នានេះ អគ្គនាយកដ្ឋានគន្លឹះនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានដាក់ឱ្យប្រើប្រាស់អនុមុខងារមួយចំនួនរួមមាន៖ អគ្គនាយកដ្ឋានគោលនយោបាយ លើអនុមុខងាររៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, នាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា លើអនុមុខងាររៀបចំចំណាយថវិកាមូលធន និង អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើអនុមុខងាររៀបចំចំណាយថវិកាមូលធន និង អនុមុខងាររៀបចំចំណាយថវិកាការទូទាត់ការខ្ចី ។

ក្នុងឆ្នាំ ២០២៥ នេះ ក្រសួង-ស្ថាប័នចំនួន ១៤ បន្ថែម (រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ) ដូចមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការប្រើប្រាស់មុខងាររៀបចំផែនការថវិកា នៃ FMIS ដូចតទៅ៖

### ១. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

១.១.*អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន* ត្រូវប្រើប្រាស់អនុមុខងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល ដោយកំណត់គោលបំណងគោលនយោបាយកម្មវិធី

សូចនាករលទ្ធផលចុងក្រោយសូចនាករលទ្ធផលក្នុងឆ្នាំ និង គោលដៅសូចនាករ ដើម្បីវាស់វែងលទ្ធផលការអនុវត្តថវិកានៅក្នុងប្រព័ន្ធ

១.២.*អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន* ត្រូវចុះប្រតិបត្តិការ ត្រួតពិនិត្យ បូកសរុប និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ទៅលើផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល បន្ទាប់ពីទទួលបានឯកសារពីអង្គភាពថវិកា និង អង្គភាពចំណុះ ក្រសួង-ស្ថាប័ន របស់ខ្លួន រួចបញ្ជូននៅក្នុងប្រព័ន្ធទៅនាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីអនុវត្តបន្ត

១.៣.*នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និង វាយតម្លៃឱ្យបានហ្មត់ចត់នៅក្នុងប្រព័ន្ធលើផែនការយុទ្ធសាស្ត្រថវិកា របស់ក្រសួង-ស្ថាប័ន ដែលបានស្នើឡើង ។

## ២. ការរៀបចំចំណូលថវិកា

២.១.*អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន, និង នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវប្រើប្រាស់អនុមុខងាររៀបចំចំណូលថវិកា សម្រាប់រៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន

២.២.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការ* របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៃក្រសួង-ស្ថាប័ន ត្រូវធ្វើការចុះប្រតិបត្តិការ និង ផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវក្នុងការរៀបចំឯកសារគម្រោងចំណូលថវិកាប្រចាំឆ្នាំ របស់អង្គភាពខ្លួនឱ្យបានរួចរាល់ រួចបញ្ជូនប្រតិបត្តិការទៅកាន់អ្នកប្រើប្រាស់ដែលទទួលសិទ្ធិអនុម័ត របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ

២.៣.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកអនុម័ត របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ* បន្ទាប់ពីទទួលបានឯកសារគម្រោងចំណូលថវិការបស់អង្គភាពខ្លួន ត្រូវធ្វើការពិនិត្យឱ្យបានហ្មត់ចត់ និង អនុម័តប្រតិបត្តិការក្នុងប្រព័ន្ធ នោះប្រតិបត្តិការនឹងបញ្ជូនស្វ័យប្រវត្តិទៅអ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកត្រួតពិនិត្យ និង បូកសរុប របស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន

២.៤.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកត្រួតពិនិត្យ របស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន* ត្រូវធ្វើការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់នៅពេលទទួលបានឯកសារគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់អង្គភាពសាមី មុននឹងបញ្ជូនទៅកាន់អ្នកប្រើប្រាស់ដែលទទួលសិទ្ធិអនុម័តនៅក្នុងប្រព័ន្ធនៃអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន

២.៥.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកអនុម័ត របស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន* ត្រូវធ្វើការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ទៅលើឯកសារគម្រោងចំណូលថវិកាប្រចាំឆ្នាំជាមួយនឹងសំណើនៃគម្រោងថវិកានៅក្នុងប្រព័ន្ធ រួចធ្វើការអនុម័តប្រតិបត្តិការក្នុងប្រព័ន្ធ ដើម្បីបញ្ជូនគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នទៅកាន់អ្នកប្រើប្រាស់នៃនាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ៣. ការរៀបចំចំណាយថវិកា

៣.១.*អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន, និង នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវប្រើប្រាស់អនុមុខងាររៀបចំចំណាយថវិកា សម្រាប់រៀបចំគម្រោងចំណាយថវិកាលម្អិតប្រចាំឆ្នាំ

៣.២. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការ របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៃក្រសួង-ស្ថាប័ន* ត្រូវធ្វើការចុះប្រតិបត្តិការ និង ផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ ក្នុងការរៀបចំឯកសារគម្រោងចំណាយថវិកាប្រចាំឆ្នាំ របស់អង្គភាពខ្លួនឱ្យបានរួចរាល់ រួចបញ្ជូនប្រតិបត្តិការទៅកាន់អ្នកប្រើប្រាស់ដែលទទួលសិទ្ធិអនុម័ត របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ

៣.៣. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកអនុម័ត របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ* បន្ទាប់ពីទទួលបានឯកសារគម្រោងចំណាយថវិការបស់អង្គភាពខ្លួន ត្រូវធ្វើការពិនិត្យឱ្យបានហ្មត់ចត់ និង អនុម័តប្រតិបត្តិការក្នុងប្រព័ន្ធ នោះប្រតិបត្តិការនឹងបញ្ជូនស្វ័យប្រវត្តិទៅអ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកត្រួតពិនិត្យ និង បូកសរុបរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន

៣.៤. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកត្រួតពិនិត្យ របស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន* ត្រូវធ្វើការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់នៅពេលទទួលបានឯកសារគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់អង្គភាពសាមី មុននឹងបញ្ជូនទៅកាន់អ្នកប្រើប្រាស់ដែលទទួលសិទ្ធិអនុម័តនៅក្នុងប្រព័ន្ធនៃអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន

៣.៥. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកអនុម័ត របស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន* ត្រូវធ្វើការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ទៅលើឯកសារគម្រោងចំណាយថវិកាប្រចាំឆ្នាំជាមួយនឹងសំណើនៃគម្រោងថវិកានៅក្នុងប្រព័ន្ធ រួចធ្វើការអនុម័តប្រតិបត្តិការក្នុងប្រព័ន្ធ ដើម្បីបញ្ជូនគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន ទៅកាន់អ្នកប្រើប្រាស់នៃនាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ៤. ការរៀបចំប្រាក់បៀវត្សមន្ត្រីរាជការ

៤.១. *អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន, និង នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវប្រើប្រាស់អនុមុខងាររៀបចំប្រាក់បៀវត្សមន្ត្រីរាជការ សម្រាប់ធ្វើការកំណត់ និង បញ្ចូលអត្រានៃគម្រោងចំណាយបន្ទុកបុគ្គលិកមន្ត្រីរាជការប្រចាំឆ្នាំ និង ការលើកគម្រោងចំណាយបន្ទុកបុគ្គលិករបស់ក្រសួង-ស្ថាប័ន

៤.២. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបញ្ចូលអត្រាបន្ទុកបុគ្គលិកមន្ត្រីរាជការ របស់នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវធ្វើការបញ្ចូលអត្រាប្រាក់បៀវត្ស និង បន្ទុកបុគ្គលិកផ្សេងៗរបស់មន្ត្រីរាជការទៅក្នុងប្រព័ន្ធ

៤.៣. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការ របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៃក្រសួង-ស្ថាប័ន* ត្រូវធ្វើការចុះប្រតិបត្តិការ និង ផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ លើគម្រោងចំណាយបន្ទុកបុគ្គលិករបស់ខ្លួនឱ្យបានត្រឹមត្រូវ រួចបញ្ជូនប្រតិបត្តិការទៅកាន់អ្នកប្រើប្រាស់ដែលទទួលសិទ្ធិអនុម័តរបស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ

៤.៤. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកអនុម័ត របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ* បន្ទាប់ពីទទួលបានឯកសារគម្រោងចំណាយបន្ទុកបុគ្គលិករបស់អង្គភាពខ្លួន ត្រូវធ្វើការពិនិត្យឱ្យបានហ្មត់ចត់ និង អនុម័តលើប្រតិបត្តិការក្នុងប្រព័ន្ធ នោះប្រតិបត្តិការនឹងបញ្ជូនស្វ័យប្រវត្តិទៅអ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកត្រួតពិនិត្យ និង បូកសរុប របស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន

៤.៥. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកត្រួតពិនិត្យរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន* ត្រូវធ្វើការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់នៅពេលទទួលបានឯកសារគម្រោងចំណាយ

បន្ទុកបុគ្គលិកប្រចាំឆ្នាំ របស់អង្គភាពសាមី មុននឹងបញ្ជូនទៅកាន់អ្នកប្រើប្រាស់ដែលទទួលសិទ្ធិអនុម័ត នៅក្នុងប្រព័ន្ធនៃអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន

៤.៦.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកអនុម័ត របស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន* ត្រូវធ្វើការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ទៅលើឯកសារគម្រោងចំណាយបន្ទុកបុគ្គលិកប្រចាំឆ្នាំជាមួយនឹងសំណើនៃគម្រោងថវិកានៅក្នុងប្រព័ន្ធ រួចធ្វើការអនុម័តប្រតិបត្តិការក្នុងប្រព័ន្ធ ដើម្បីបញ្ជូនគម្រោងចំណាយបន្ទុកបុគ្គលិកប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន ទៅកាន់អ្នកប្រើប្រាស់នៃនាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ៥. ការរៀបចំសូចនាករសមិទ្ធកម្ម

៥.១.*អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន, និង នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវប្រើប្រាស់អនុមុខងាររៀបចំសូចនាករសមិទ្ធកម្ម សម្រាប់រៀបចំ គោលដៅសូចនាករទៅតាមឆ្នាំនីមួយៗនៃសូចនាករលទ្ធផលចុងក្រោយ និង សូចនាករលទ្ធផលក្នុងឆ្នាំទៅតាមចំណាត់ថ្នាក់កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព ដែលជាសមិទ្ធកម្មរបស់អង្គភាព និង របាយការណ៍សមិទ្ធកម្ម

៥.២.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការ របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៃក្រសួង-ស្ថាប័ន* ត្រូវធ្វើការបញ្ចូលសូចនាករ គោលដៅសូចនាករ វឌ្ឍនភាព នៃសូចនាករលទ្ធផលចុងក្រោយ និង សូចនាករលទ្ធផលក្នុងឆ្នាំ និង បញ្ចូលរបាយការណ៍សមិទ្ធកម្មរបស់អង្គភាពខ្លួនក្នុងប្រព័ន្ធ នៅពេលរៀបចំឯកសាររួចរាល់ និង បញ្ជូនប្រតិបត្តិការបន្តទៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន ដែលទទួលសិទ្ធិជាអ្នកត្រួតពិនិត្យ និង បូកសរុបនៅក្នុងប្រព័ន្ធ ។ ដោយឡែក ចំពោះអង្គភាពថវិកា និង អង្គភាពចំណុះក្រសួង-ស្ថាប័ន ដែលពុំទាន់មានប្រព័ន្ធប្រើប្រាស់ អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុជាអ្នកទទួលបន្ទុកបញ្ចូលក្នុងប្រព័ន្ធជំនួស

៥.៣.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកត្រួតពិនិត្យ និង បូកសរុបនៅក្នុងប្រព័ន្ធ របស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន* ត្រូវធ្វើការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់នៅពេលទទួលបានឯកសារពីអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និង អង្គភាពចំណុះក្រសួងរបស់ខ្លួន រួចបញ្ជូនទៅកាន់អ្នកប្រើប្រាស់ដែលជាអ្នកត្រួតពិនិត្យ របស់នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីអនុវត្តនៅដំណាក់កាលបន្តបន្ទាប់ទៀត ។

**សម្គាល់៖ អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកត្រួតពិនិត្យរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន ត្រូវធ្វើការចុះប្រតិបត្តិការថវិកាជំនួសអង្គភាពថវិកាដែលមិនទាន់ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធរៀបចំផែនការថវិកាគ្រប់អនុមុខងារទាំងអស់ ។*

## ៦.ការអនុវត្តនៅនាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៦.១.សម្រាប់ផែនការថវិកានៃក្រសួង-ស្ថាប័ន បន្ទាប់ពីទទួលបានការសម្រេចនៅក្នុងដំណាក់កាល ប្រជុំពិភាក្សាគម្រោងថវិកាកម្រិតបច្ចេកទេស និង កម្រិតថ្នាក់ដឹកនាំជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចហើយ *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិកែសម្រួលប្រតិបត្តិការផែនការថវិកាទៅតាមក្រសួង-ស្ថាប័ននៅក្នុងប្រព័ន្ធ* ត្រូវធ្វើការពិនិត្យ និង កែសម្រួលលើប្រតិបត្តិការផែនការថវិការបស់ក្រសួង-ស្ថាប័នដែលខ្លួនទទួលបន្ទុក ទៅតាមដំណាក់កាលនៃការពិភាក្សាគម្រោងថវិកានីមួយៗដោយឡែកពីគ្នា និង បញ្ជូនប្រតិបត្តិការផែនការថវិកានោះបន្តទៅ *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកអនុម័តតាមវិស័យ* នៅក្នុងដំណាក់កាលនីមួយៗដោយឡែកពីគ្នា

៦.២.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តតាមវិស័យ* ត្រូវធ្វើការត្រួតពិនិត្យ សំណើនៃគម្រោងថវិកានៅក្នុងប្រព័ន្ធដែលបានកែសម្រួលរួច នៅក្នុងដំណាក់កាលនៃការពិភាក្សាគម្រោងថវិកានីមួយៗនៃចំណុច ៦.១ ខាងលើ និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់នូវគម្រោងថវិកាដែលបានសម្រេចនៅក្នុងដំណាក់កាលនីមួយៗនៃការពិភាក្សាគម្រោងថវិកា រួចធ្វើការអនុម័តគម្រោងថវិកានោះទៅតាមដំណាក់កាលនៃការពិភាក្សាគម្រោងថវិកានីមួយៗដោយឡែកពីគ្នា ។ បន្ទាប់ពីបញ្ចប់ដំណាក់កាលនៃការពិភាក្សាគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំ ប្រព័ន្ធនឹងបញ្ជូនគម្រោងថវិកាបន្តទៅកាន់ដំណាក់កាលបន្ទាប់

៦.៣.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិកែសម្រួលប្រតិបត្តិការផែនការថវិកា* សម្រាប់ដំណាក់កាលបន្ទាប់ពីបញ្ចប់កិច្ចប្រជុំពិភាក្សាគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំ ត្រូវធ្វើការកែសម្រួលប្រតិបត្តិការគម្រោងថវិកានៅក្នុងប្រព័ន្ធទៅតាមដំណាក់កាលដោយឡែកពីគ្នា ផ្អែកលើលទ្ធផលនៃការអនុម័តថវិកាក្នុងដំណាក់កាលនីមួយៗ រួមមាន៖ ការអនុម័តរបស់គណៈរដ្ឋមន្ត្រី ការអនុម័តរបស់រដ្ឋសភា និង ការអនុម័តរបស់ព្រឹទ្ធសភា រួចបញ្ជូនបន្តទៅកាន់អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តគម្រោងថវិកាទៅតាមដំណាក់កាលនីមួយៗ

៦.៤.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តគម្រោងថវិកា* សម្រាប់ដំណាក់កាលបន្ទាប់ពីបញ្ចប់កិច្ចប្រជុំពិភាក្សាគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំ ត្រូវបន្តធ្វើការត្រួតពិនិត្យគម្រោងថវិកានៅក្នុងប្រព័ន្ធដែលបានកែសម្រួលរួច និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ជាមួយនឹងគម្រោងថវិកាដែលបានអនុម័តនៅក្នុងដំណាក់កាលនៃការពិភាក្សាគម្រោងថវិកានីមួយៗនៃចំណុច ៦.៣ ខាងលើ រួចធ្វើការអនុម័តគម្រោងថវិកានោះនៅក្នុងប្រព័ន្ធទៅតាមដំណាក់កាលនៃការពិភាក្សាគម្រោងថវិកានីមួយៗដោយឡែកពីគ្នា ។ បន្ទាប់ពីបញ្ចប់ការអនុម័តនៅក្នុងប្រព័ន្ធនៅគ្រប់ដំណាក់កាល ប្រព័ន្ធនឹងបញ្ជូនគម្រោងថវិកាបន្តទៅអ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តចុងក្រោយ

៦.៥.*អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តច្បាប់ថវិកា* ត្រូវធ្វើការអនុម័តទៅលើច្បាប់ថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចប់ដំណើរការនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំនៅក្នុងប្រព័ន្ធ នៅពេលដែលទទួលបានព្រះរាជក្រមប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ។

ក្រសួង-ស្ថាប័ន, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធនានាត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

*ថ្ងៃពុធ ២ កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី ១ ខែមករា ឆ្នាំ ២០២៥*

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  *"ដើម្បីគោរពជូនជ្រាប"*
- អគ្គនាយកដ្ឋានថវិកា
- គ្រប់ក្រសួង-ស្ថាប័នដែលប្រកាសឱ្យប្រើប្រាស់មុខងាររៀបចំផែនការថវិកានៃ FMIS
  *"ដើម្បីអនុវត្ត"*
- ឯកសារ កាលប្បវត្តិ

*ឧបសម្ព័ន្ធនៃសេចក្តីណែនាំលេខ ០០៦ សហវ.ស.ណ.ន.ប.គ.ហ ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០២៥*
*ស្តីពី ការដាក់ឱ្យប្រើប្រាស់មុខងាររៀបចំផែនការថវិកា*
*នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)*
*សម្រាប់ក្រសួង-ស្ថាប័នចំនួន ១៤ និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ៩ ចាប់ពីឆ្នាំ ២០២៥ តទៅ*

## បញ្ជីឈ្មោះក្រសួង-ស្ថាប័ន និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ

### ក.បញ្ជីឈ្មោះក្រសួង-ស្ថាប័នចំនួន ១៤ ដែលចាប់ផ្តើមអនុវត្តក្នុងឆ្នាំ ២០២៥

| | |
|---|---|
| ១. ក្រសួងអប់រំ យុវជន និងកីឡា | ៩. ទីស្តីការគណៈរដ្ឋមន្ត្រី |
| ២. ក្រសួងសុខាភិបាល | ១០. ក្រសួងរ៉ែ និងថាមពល |
| ៣. ក្រសួងព្រះបរមរាជវាំង | ១១. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ៤. ក្រសួងមហាផ្ទៃ | ១២. ក្រសួងមុខងារសាធារណៈ |
| ៥. ក្រសួងធម្មការ និងសាសនា | ១៣. ក្រសួងផែនការ |
| ៦. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ១៤. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ៧. ក្រសួងអធិការកិច្ច | |
| ៨. ក្រសួងការពារជាតិ | |

### ខ.បញ្ជីឈ្មោះអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញដែលចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ ២០២៥

| | |
|---|---|
| I.ក្រសួងអប់រំ យុវជន និងកីឡា | II.ក្រសួងក្រសួងសុខាភិបាល |
| ១. វិទ្យាស្ថានជាតិអប់រំ | ១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| ២. វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | III.ក្រសួងមហាផ្ទៃ |
| ៣.គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | ១. អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| | ២. អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| | ៣. អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក |
| | ៤. គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌អំពើធ្វើទុក្ខបុកម្នេញ ឬទារុណកម្ម (គ.ជ.ប.ទ) |
| | IV.ក្រសួងមុខងារសាធារណៈ |
| | ១. សាលាភូមិន្ទរដ្ឋបាល |